ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការក្រសួងយុត្តិធម៌

លេខ: ១១៥ ភ.ឃ.កសក.ក.ក/១១

៥៧០ កសក-ក.ក

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ប្រកាសរួម

ស្ដីពី

## ទម្រង់បែបបទនៃកំណត់ហេតុបទល្មើសជលផល

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងយុត្តិធម៌

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីជលផល

-បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្ដីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញប្រកាសលេខ ៣៨៦ ប្រក.កសក.ប ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៧ ស្ដីពីការរៀបចំ និងការ

ផ្លូវសម្ដេចសុធារស ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទលេខ : 023 216 322/023 212 693

ប្រព្រឹត្តទៅរបស់រដ្ឋបាលជលផល

-បានឃើញប្រកាសលេខ ៦៨១ ប្រក.កសក.ប ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ និងមន្ទីរពិសោធន៍ចំណុះនាយកដ្ឋាន និងវិទ្យាស្ថានក្រោមឱវាទរដ្ឋបាលជលផល

-យោងតាមការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១** :

ត្រូវបានបង្កើត និងអនុញ្ញាតឱ្យរដ្ឋបាលជលផលប្រើប្រាស់ជាផ្លូវការនូវទម្រង់បែបបទនៃកំណត់ហេតុបទល្មើសជលផល និងសំណុំលិខិតដោះស្រាយបទល្មើសជលផលសម្រាប់កសាងសំណុំរឿងនៃបទល្មើសជលផល និងបំពេញសំណុំបែបបទនៅក្នុងប្រតិបត្តិការឱ្យបានសមស្របតាមច្បាប់ស្ដីពីជលផល និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

សំណុំលិខិតសម្រាប់ដោះស្រាយបទល្មើសជលផល មានដូចខាងក្រោម ៖

១-លិខិតបញ្ជូនសំណុំរឿង

២-ដីកាអម

៣-របាយការណ៍សរុប

៤-កំណត់ហេតុបញ្ចប់ការស៊ើបអង្កេត

៥-កំណត់ហេតុឆែកឆេរ

៦-សេចក្ដីសម្រេចព្រមាន

៧-កំណត់ហេតុអនុញ្ញាតឱ្យវិលត្រឡប់ទៅ...............

៨-កំណត់ហេតុផ្ដល់ដំណឹងអំពីការបញ្ចប់ការឃាត់ខ្លួន

៩-កំណត់ហេតុប្រគល់-ទទួលជនសង្ស័យ

១០-កំណត់ហេតុស្ដាប់ចម្លើយ

១១-កំណត់ហេតុចាប់ខ្លួន

១២-កំណត់ហេតុឃាត់ខ្លួន

១៣-សេចក្ដីសម្រេចស្ដីពីការពិន័យអន្តរការណ៍លើបទល្មើសជលផល

១៤-កំណត់ហេតុនៃបទល្មើសជលផល

១៥-សលាកប័ត្រទោសទណ្ឌ

១៦-កំណត់ហេតុប្រគល់-ទទួលថែរក្សាវត្ថុតាងដកហូតឃាត់ទុក

១៧-សេចក្ដីសម្រេច

១៨-កំណត់ហេតុ...............

១៩-កំណត់ហេតុដកហូតឃាត់ទុកវត្ថុតាង

២០-កំណត់ហេតុបទល្មើសជលផល...............

២១-លិខិតទទួលស្គាល់កំហុស

២២-ព្រឹត្តិបត្រព័ត៌មានជនសង្ស័យ

Next ទំព័រ 5

២៣-លិខិតកោះហៅ

២៤-កំណត់ហេតុទទួលព័ត៌មាន

២៥-កំណត់ហេតុចុះពិនិត្យកន្លែងកើតហេតុ

២៦-កំណត់ហេតុត្រួតពិនិត្យ................

២៧-បញ្ជីនៃការឃាត់ខ្លួន

២៨-បញ្ជីសារពើភ័ណ្ឌវត្ថុតាងដកហូតឃាត់ទុក

២៩-បញ្ជីសរុបកំណត់ហេតុឃាត់ខ្លួន

គំរូសំណុំលិខិតសម្រាប់ដោះស្រាយបទល្មើសជលផលមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសរួមនេះ។

**ប្រការ ២** :

ប្រកាស ឬសេចក្ដីសម្រេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៣** :

រដ្ឋបាលជលផល អគ្គនាយកដ្ឋាននៃក្រសួងយុត្តិធម៌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ ២០១១

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** **រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

ចាន់ សារុន អង្គ វង្សវឌ្ឍានា

**<u>កន្លែងទទួល</u>** :

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី

-តុលាការកំពូល

-មហាអយ្យការអមតុលាការកំពូល

-សាលាឧទ្ធរណ៍

-មហាអយ្យការអមសាលាឧទ្ធរណ៍

-សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី ខេត្ត

-គ្រប់ក្រសួង-ស្ថាប័ន

-គ្រប់សាលារាជធានី ខេត្ត

-ដូចប្រការ ៣

-ឯកសារ-កាលប្បវត្តិ